


# កែឆ្នៃប្រើឡើងវិញ ប្រេងម៉ាស៊ីន និងតម្រងដែលប្រើប្រាស់រួចហើយ

## តើហេតុអ្វីបានជាកែឆ្នៃប្រើឡើងវិញនូវប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយ ?

- ប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយមានជាតិពុលជាច្រើន ។ ពេលយកប្រេងម៉ាស៊ីនប្រើប្រាស់រួចហើយទៅចាក់ចោលមិនត្រឹមត្រូវ ជាតិពុលនេះនឹងជ្រាបចូលទៅក្នុងធាតុទឹកនៅក្នុងដី ធ្វើឲ្យខូចខាតដល់បរិស្ថាន ។

## តើលោកអ្នកត្រូវធ្វើដូចម្តេច ជាមួយប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយ ?

- ត្រូវកែឆ្នៃប្រើឡើងវិញនូវប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយ ។ ប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយមិនត្រូវចាក់ចូលទៅក្នុងដី, នៅលើផ្លូវថ្នល់, លូបង្ហូរទឹក, ធុងសំរាម ឬចាក់ចូលទៅក្នុងបំពង់បង្ហូរទឹកនៅក្នុងផ្ទះរបស់លោកអ្នកទេ ។ ប្រេងម៉ាស៊ីនមួយហ្គាឡុង អាចធ្វើឲ្យខូចទឹកចំនួនមួយលានហ្គាឡុង ។

- សូមយកប្រេងម៉ាស៊ីនស្អាតដែលប្រើប្រាស់រួចហើយ ទៅកាន់កន្លែងប្រមូលប្រេងម៉ាស៊ីន ដែលមានការអនុញ្ញាត* ដូចជាហាងសាំង, ហាងលក់គ្រឿងបន្លាស់រថយន្ត ( Kragen, AutoZone, Pep Boys, etc. ) ឬហាងដូរប្រេង ( Jiffy Lube, EZ Lube, etc. ) ។ យកល្អលោកអ្នកគួរទូរស័ព្ទទៅកន្លែងទាំងអស់នោះជាមុន មុនពេលលោកអ្នកយកប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយទៅកាន់ទីនោះ ថាតើលោកអ្នកអាចយកទៅចំនួនប៉ុន្មាន Quarts ឬប៉ុន្មាន Gallons ហើយនិងពេលវេលាដែលគេបើក ឬធ្វើការ ។

* សូមរកមើលផ្លាកសញ្ញានេះ នៅកន្លែងប្រមូលប្រេងម៉ាស៊ីនដែលមានការអនុញ្ញាតនៅជិតគេហស្ថានរបស់លោកអ្នក

RECYCLE USED OIL

## តើខ្ញុំអាចបន្តប្រើប្រាស់ប្រេងម៉ាស៊ីនដែលសំអាតរួចហើយដូចម្តេចទៅ ?

- ពេលលោកអ្នកដូរប្រេងម៉ាស៊ីន, ត្រូវចាក់ប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយនោះទៅក្នុងកំប៉ុងប្រេងប្លាស្ទិកទទេ, ស្អាត និងមានគំរបបិទយ៉ាងជិត ។

- មិនត្រូវលាយប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយជាមួយប្រេងសាំង, ទឹកការពារកក antifreezer ឬជាមួយនិងជាតិគីមីដទៃផ្សេងទៀតឡើយ ។ ការលាយប្រេងម៉ាស៊ីនដែលប្រើប្រាស់រួចហើយជាមួយអ្វីផ្សេងទៀត នឹងធ្វើឲ្យខូចប្រេងម៉ាស៊ីននោះ ។ ប្រេងម៉ាស៊ីនខូចមិនអាចយកមកប្រើប្រាស់ឡើងវិញបានទេ គឺត្រូវយកទៅកន្លែងប្រមូលប្រេងម៉ាស៊ីនដើម្បីឲ្យគេយកទៅចោល ។

## ចុះអំពីតម្រងប្រេងវិញ ?

- សូមសំរក់ប្រេងម៉ាស៊ីនចេញឲ្យអស់ពីតម្រងប្រេងដែលប្រើប្រាស់រួចហើយ រួចដាក់ទៅក្នុងស្បោងប្លាស្ទិកបិទមាត់ឲ្យជិត ឬដាក់ទៅក្នុងកំប៉ុងកាហ្វេដែលមានគំរប ឬមួយដាក់ទៅក្នុងធុងអ្វីដែលមិនលេចមកក្រៅ ។

- យកតម្រងប្រេងម៉ាស៊ីននោះ ទៅកាន់កន្លែងប្រមូលប្រេងម៉ាស៊ីន ដើម្បីឲ្យគេបោះចោលដោយត្រឹមត្រូវ ។ សូមចូលមើលកម្មវិធីពិស្តារនៅគេហទំព័រ www.888CleanLA.com ។

យើងសូមអរគុណលោកអ្នកក្នុងការកែឆ្នៃប្រើឡើងវិញ ដើម្បីថែរក្សាភូមិដ្ឋានលោកអ្នកឲ្យបានស្អាតល្អ ហើយនិងដើម្បីជួយថែរក្សាការពារបរិស្ថាន ។

This message is brought to you by the County of Los Angeles Department of Public Works and funded by a grant from the California Integrated Waste Management Board.
Zero Waste -- You Make It Happen!